ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ផែនការសកម្មភាព ស្ដីពីការអប់រំបរិយាបន្ន ២០២៤-២០២៨







# អារម្ភកថា

រាជរដ្ឋាភិបាលកម្ពុជា មានការប្ដេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការលើកកម្ពស់សិទ្ធិរបស់ជនមានពិការភាព ដោយបានផ្ដល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិជនពិការ (UNCRPD) និងបានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្ដីពីការអប់រំ និងច្បាប់ស្ដីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។ ក្នុងបរិបទនេះ ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តគោលនយោបាយ ស្ដីពីការអប់រំបរិយាបន្នក្នុងឆ្នាំ២០១៨ និងផែនការសកម្មភាព ស្ដីពីការអប់រំបរិយាបន្ន២០១៩-២០២៣។

ការអនុវត្តផែនការសកម្មភាព ស្ដីពីការអប់រំបរិយាបន្ន២០១៩-២០២៣ បាននាំមកនូវវឌ្ឍនភាពគួរកត់សម្គាល់។ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់បញ្ចូលមុខវិជ្ជាអប់រំបរិយាបន្នទៅក្នុងកម្មវិធីបណ្ដុះបណ្ដាលនៅតាមគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀនគ្រប់កម្រិត និងបានបណ្ដុះបណ្ដាលគ្រូជំនាញ និងអប់រំបរិយាបន្នប្រមាណ ៤០០០នាក់ សម្រាប់វិទ្យាល័យអប់រំពិសេស ថ្នាក់សមាហរណកម្ម និងថ្នាក់អប់រំបរិយាបន្ននៅទូទាំងប្រទេស។ ក្រសួងបានសហការជាមួយដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ និងសហគមន៍ អនុវត្តកម្មវិធីអប់រំបរិយាបន្ននៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ការអប់រំតាមផ្ទះ ដើម្បីផ្ដល់សេវាគាំទ្រកុមារមានពិការភាព ប្រមាណ១៦០០០នាក់។

ដើម្បីធានាថាកុមារមានពិការភាពទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំ **ផែនការសកម្មភាព ស្ដីពីការអប់រំបរិយាបន្ន២០២៤-២០២៨** ដោយផ្អែកលើគោលនយោបាយ ស្ដីពីការអប់រំបរិយាបន្នឆ្នាំ២០១៨ អនុសាសន៍ពីការស្រាវជ្រាវឆ្នាំ២០២៣ និងឧត្តមានុវត្តន៍នៃការអនុវត្តផែនការសកម្មភាព ស្ដីពីការអប់រំបរិយាបន្ន២០១៩-២០២៣។ ផែនការនេះ ត្រូវបានបង្កើតឡើងដោយមានការពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ គ្រូបង្រៀន អ្នកអាណាព្យាបាល និងអ្នកពាក់ព័ន្ធ។ ផែនការនេះ ជាផែនទីបង្ហាញផ្លូវ ដែលមានយុទ្ធសាស្ត្រ និងសកម្មភាពអាទិភាពសំខាន់ៗ ដើម្បីធានាការផ្ដល់សេវាអប់រំបរិយាបន្ន ដល់ជនមានពិការភាព ជាពិសេសកុមារមានពិការភាពប្រកបដោយគុណភាព សមធម៌ បរិយាបន្ន និងលើកកម្ពស់ការសិក្សាពេញមួយជីវិត ក្នុងការរួមចំណែកដល់ការអភិវឌ្ឍសង្គមជាតិ។ ការអនុវត្តផែនការនេះឱ្យទទួលបានជោគជ័យ តម្រូវឱ្យមានការប្រឹងប្រែងរួមគ្នារវាងអង្គភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ គ្រឹះស្ថានសិក្សា ដៃគូអភិវឌ្ឍន៍ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ មន្ត្រីគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធទាំងអស់ ជាពិសេសមូលនិធិភាពជាដៃគូអភិវឌ្ឍន៍សមត្ថភាពវិស័យអប់រំ (CDPF) មូលនិធិអង្គការសហប្រជាជាតិ ដើម្បីកុមារប្រចាំកម្ពុជា និងការិយាល័យប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក(យូនីសេហ្វ) ដែលបានចូលរួមសហការ និងគាំទ្រដល់ការរៀបចំផែនការសកម្មភាពអប់រំបរិយាបន្ន ២០២៤-២០២៨ ឱ្យសម្រេចជាស្ថាពរ។

ថ្ងៃ ចន្ទ ១៣កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# មាតិកា


ពាក្យបំព្រួញ ........ ១

១. សាវតារ ........ ៣

*១.១. បរិបទសកលលោក និងតំបន់នៃកុមារមានពិការភាព ........ ៣*

*១.២. បរិបទប្រទេស ........ ៣*

*១.៣. សមិទ្ធផលសំខាន់ៗនៃផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្នឆ្នាំ២០១៩-២០២៣ ........ ៦*

២. ការវិភាគស្ថានភាពអំពីកុមារមានពិការភាព ........ ៧

*២.១. ការវិភាគស្ថានភាពអំពីការអប់រំបរិយាបន្ននៅក្នុងប្រទេសកម្ពុជា ........ ១០*

*២.២. បញ្ហាប្រឈម និងរនាំងខូបសគ្គចំពោះការអប់រំបរិយាបន្ន ........ ១០*

*២.៣. អនុសាសន៍លើគោលនយោបាយ ........ ១០*

៣. ចក្ខុវិស័យ ........ ១៣

៤. គោលបំណង ........ ១៤

៥.វិសាលភាព ........ ១៥

៦. យុទ្ធសាស្ត្រ ........ ១៥

៧. ផែនការសកម្មភាព ........ ១៨

៨. យន្តការអនុវត្ត និងការគ្រប់គ្រង ........ ២១

៩. ភាគីពាក់ព័ន្ធ ........ ២១

១០. វិភាជន៍ថវិកា និងធនធាន ........ ២២

១១. ការពិនិត្យតាមដាន និងវាយតម្លៃ ........ ២៣

១២. សន្និដ្ឋាន ........ ២៣

ឧបសម្ព័ន្ធ ........ ២៥

ឧបសម្ព័ន្ធ ១. តារាងម៉ាទ្រិចនៃផែនការសកម្មភាពសម្រាប់ការអប់រំបរិយាបន្ន ........ ២៥

ឧបសម្ព័ន្ធ ២. ទម្រង់ការអប់រំបរិយាបន្ន ........ ៥៩

*ដូចម្តេចដែលហៅថាការអប់រំបរិយាបន្ន? ........ ៥៩*

*ប្រព័ន្ធការអប់រំបរិយាបន្ន ........ ៥៩*

*ក្របខណ្ឌអប់រំបរិយាបន្នសម្រាប់ពិការភាព ........ ៦០*

ឧបសម្ព័ន្ធ ៣. សទ្ទានុក្រមនៃវាក្យសព្ទបរិយាបន្នសម្រាប់ពិការភាព ........ ៦២

# ពាក្យបំព្រួញ

- **AAR Japan** ៖ សមាគមន៍សម្រាប់ជំនួយ និងសង្គ្រោះ នៃប្រទេសជប៉ុន
- **CCAMH** ៖ មជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារ និងយុវវ័យកម្ពុជា
- **CCC** ៖ មជ្ឈមណ្ឌលសុខភាពកុមារ
- **CYWD** ៖ កុមារ និងយុវជនមានពិការភាព
- **CP-SSIP** ៖ ផែនការអនុវត្តយុទ្ធសាស្ត្រផ្នែកគាំពារកុមារ
- **CRPD** ៖ អនុសញ្ញាស្តីពីសិទ្ធិជនមានពិការភាព
- **CRS** ៖ អង្គការកាតូលិក រីលីស សឺវីស
- **CSES** ៖ ការស្រាវជ្រាវស្ទង់មតិសេដ្ឋកិច្ច-សង្គមកម្ពុជា
- **CWD** ៖ កុមារមានពិការភាព
- **DAC** ៖ ក្រុមប្រឹក្សាសកម្មភាពជនមានពិការភាព
- **DDSP** ៖ អង្គការកម្មវិធីសេវាអភិវឌ្ឍជនពិការ(ខេត្តពោធិ៍សាត់)
- **DIPAS** ៖ គោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីពិការភាព-បរិយាបន្ន
- **DOE** ៖ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- **DP** ៖ ដៃគូអភិវឌ្ឍន៍
- **IE** ៖ ការអប់រំបរិយាបន្ន
- **EMIS** ៖ ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ
- **EF** ៖ មូលនិធិសមធម៌
- **ESP** ៖ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ
- **NGOs** ៖ អង្គការក្រៅរាជរដ្ឋាភិបាលជាតិ/អង្គការអន្តរជាតិ
- **LiFE** ៖ ការសិក្សាគឺដើម្បីទាំងអស់គ្នា
- **MoEYS** ៖ ក្រសួងអប់រំ យុវជន និងកីឡា
- **MoH** ៖ ក្រសួងសុខាភិបាល
- **MoLVT** ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- **MoP** ៖ ក្រសួងផែនការ
- **MoSAVY** ៖ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- **NIE** ៖ វិទ្យាស្ថានជាតិអប់រំ
- **NISE** ៖ វិទ្យាស្ថានជាតិអប់រំពិសេស
- **NCDP** ៖ មជ្ឈមណ្ឌលជាតិនៃជនពិការ
- **PoE** ៖ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- **PB** ៖ ថវិកាកម្មវិធី/ថវិការដ្ឋ

- **PTTC** ៖ សាលាគរុកោសល្យ និងវិក្រឹតការ រាជធានី ខេត្ត
- **PWD** ៖ ជនមានពិការភាព
- **RGC** ៖ រាជរដ្ឋាភិបាលកម្ពុជា
- **SDGs** ៖ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព
- **SED** ៖ នាយកដ្ឋានអប់រំពិសេស
- **STEM** ៖ វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- **UNESCO** ៖ អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌អង្គការសហប្រជាជាតិ
- **UNICEF** ៖ មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ

## ១. សេចក្តីផ្តើម

នៅលើសកលលោក កុមារប្រមាណ២៤០លាននាក់ ធ្លាប់ជួបប្រទះប្រភេទណាមួយនៃពិការភាព ក្នុងចំណោមកុមារ១០នាក់មានកុមារម្នាក់មានពិការភាព។ គម្លាតខុសគ្នានៃប្រភេទពិការភាព អាស្រ័យនៅតាមតំបន់នីមួយៗ។ ឧទាហរណ៍ កុមារ៨នាក់ក្នុងចំណោមកុមារ១០០នាក់ ក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិកមានពិការភាពចំណែកឯអត្រាកំណើនឡើងដល់១៣នាក់ ក្នុងចំណោម១០០នាក់ នៅក្នុងតំបន់មជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើង។ *ស្ថានភាពលំបាកផ្នែកចិត្តសាស្ត្រផ្សេងៗមានលក្ខណៈខុសៗគ្នាក្នុងចំណោមកុមារមានពិការភាពទាំងនេះ*[1] ។

យោងតាមជំរឿនសកលកម្ពុជានៅឆ្នាំ២០១៩ បានបង្ហាញថា ប្រជាជន៦៩០ពាន់នាក់ ប្រហែល៤.៩% នៃប្រជាជន ១៤.១លាននាក់ មានអាយុ៥ឆ្នាំ និងលើសពីនេះមានប្រភេទពិការភាពណាមួយដែលក្នុងនោះមាន ៣៨ពាន់នាក់ គឺជាកុមារដែលមានអាយុចន្លោះពី៥ឆ្នាំ ដល់១៤ឆ្នាំ។ ជំរឿននេះបានបង្ហាញថា ៤៩% នៃកុមារមានអាយុចន្លោះពី៥ឆ្នាំ ទៅ៩ឆ្នាំ មានពិការភាព ពីកម្រិតមធ្យម ទៅធ្ងន់ធ្ងរ មិនបានចូលសាលារៀន។ ការសិក្សាស្រាវជ្រាវមួយរបស់អង្គការយូនីសេហ្វ ផ្អែកលើការស្ទង់មតិ សេដ្ឋកិច្ចសង្គមកម្ពុជា២០១៩-២០២០ ក៏បានបង្ហាញថា អត្រាបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សាមានប្រមាណ២៣% ក្នុងចំណោមកុមារមានពិការភាព បើប្រៀបធៀបទៅនឹង៨១% នៃកុមារមិនមានពិការភាព។ កត្តានេះនាំឱ្យមានអត្រាអក្ខរកម្មទាបក្នុងចំណោមជនមានពិការភាពនៅក្នុងប្រទេសកម្ពុជា។

### ១.១ បរិបទសកលលោក និងតំបន់នៃកុមារមានពិការភាព

*ពិការភាព គឺជាឧបសគ្គមួយក្នុងចំណោមឧបសគ្គធ្ងន់ធ្ងរបំផុតចំពោះការអប់រំទូទាំងសកលលោក។*

ការរំលោភបំពានសិទ្ធិចំពោះការសិក្សានៃកុមារមានពិការភាពកើតមានជារឿយៗ ហើយកុមារមានពិការភាពត្រូវបានបដិសេធឱកាសចូលរួមក្នុងសហគមន៍ ការងារ និងការសម្រេចចិត្តដែលប៉ះពាល់យ៉ាងខ្លាំងដល់ពួកគេ។ ទោះបីជាវឌ្ឍនភាពពាសពេញសកលលោក ក្នុងការធានាដល់អ្នកសិក្សាទាំងអស់ឱ្យទទួលបានការអប់រំប្រកបដោយគុណភាពក្តី ក៏ជនដែលងាយរងគ្រោះបំផុតត្រូវបានគេមើលរំលង ឬបំភ្លេចចោល។ កុមារមានពិការភាពគឺស្ថិតក្នុងចំណោមជនដែលត្រូវបានគេមើលរំលង ឬផាត់ចេញ កំពុងជួបប្រទះនូវរនាំងឧបសគ្គកាយសម្បទា សង្គម នយោបាយ និងស្ថាប័នជាច្រើន។ ការផាត់ចេញពីការអប់រំ បានធ្វើឱ្យមានការលំបាកមិនចេះចប់នៃវដ្តពិការភាព និងភាពក្រីក្រ។ ខណៈដែលក្របខណ្ឌសិទ្ធិមនុស្ស អន្តរជាតិបានផ្លាស់ប្តូរជីវិតនៅគ្រប់ទីកន្លែង ជនមានពិការភាពមិនបានទទួលផលប្រយោជន៍ដូចគ្នាទេ។ ប្រសិនបើមិនបានគិតពីសិទ្ធិមនុស្ស ឬស្ថានភាពសេដ្ឋកិច្ចនៃប្រទេសនោះទេ សិទ្ធិរបស់ជនមានពិការភាពត្រូវបានដាក់បញ្ចូលក្រោយគេ។

អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ គឺជាការឆ្លើយតបទៅនឹងសហគមន៍អន្តរជាតិចំពោះប្រវត្តិដ៏យូរលង់នៃការរើសអើង ការផាត់ចេញ និងការប្រកាន់ជាតិសាសន៍ នៃជនមានពិការភាព។ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ បានចង្អុលបង្ហាញពីកាតព្វកិច្ចរដ្ឋហត្ថលេខី ក្នុងការផ្តល់ការអប់រំបរិយាបន្ន។ មាត្រា ២៤ នៃអនុសញ្ញានេះបានអំពាវនាវដល់ការអភិវឌ្ឍនៃការអប់រំបរិយាបន្នគ្រប់កម្រិតសិក្សា៖ ប្រទេសចុះហត្ថលេខី

[1] *United Nations Children's Fund, Seen, Counted, Included: Using data to shed light on the well-being of children with disabilities, UNICEF, 2021.*

ត្រូវជានាថា ច្បាប់នានាលើកកម្ពស់សិទ្ធិជនមានពិការភាពចំពោះការអប់រំនៅគ្រប់កម្រិតសិក្សា និងអនុញ្ញាតឱ្យពួកគេបានសិក្សាជាមួយនឹងសិស្សដទៃទៀតក្នុងសាលារៀនបរិយាបន្ន។

ការផាត់ចេញពីសង្គម គឺជាឧបសគ្គដ៏ធំមួយក្នុងការកាត់បន្ថយ និងលុបបំបាត់ភាពក្រីក្រ និងសុខុមាលភាពជាតិ ហើយជាប្រភពនៃការឈឺចាប់ ការរើសអើង ឧក្រិដ្ឋកម្ម និងការអភិវឌ្ឍធនធានមនុស្ស។ ជនក្រីក្រ គ្រួសារ កុមារកំព្រា ជនកំព្រា និងជនមានពិការភាពទាំងឡាយគឺជាជនដែលងាយរងគ្រោះចំពោះការផាត់ចេញពីសង្គម។ ជនមានពិការភាព គឺជាបន្ទុករបស់សង្គម។ ដូច្នេះ ពួកគេមិនត្រូវទទួលការរើសអើងពីសង្គមទាក់ទងនឹង ការអប់រំ សហគមន៍ ពលកម្ម កន្លែងការងារ និងទីសាធារណៈ។ ការអប់រំជាប្រភពមូលដ្ឋានដ៏សំខាន់មួយនៃការរើសអើងក្នុងសង្គម។ រដ្ឋធម្មនុញ្ញកម្ពុជា និងគោលនយោបាយស្តីពីការអប់រំបរិយាបន្នឆ្នាំ២០១៨ ដែលអនុលោមតាម សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សឆ្នាំ១៩៤៨ បានចែងថា មនុស្សគ្រប់រូបកើតមកមានសិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូរ និងមានភាពស្មើគ្នា ហើយអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធជនពិការជានាថា ជនមានពិការភាពគ្រប់រូបរីករាយ ឬអនុវត្តសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានទាំងអស់ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច វប្បធម៌ សង្គមស៊ីវិល ឬវិស័យដទៃទៀតឈរលើមូលដ្ឋានស្មើភាពគ្នា។

ការពិនិត្យមើលអំពីគោលនយោបាយដែលមានស្រាប់ពាក់ព័ន្ធនឹងការអប់រំបរិយាបន្ននៅកម្ពុជា បានរកឃើញថាមានតែគោលនយោបាយ៣ទេក្នុងចំណោមគោលនយោបាយ១៣ដែលបានយកមកសិក្សា និងពិនិត្យដែលបានឱ្យនិយមន័យអំពីពិការភាពច្បាស់លាស់។ ឯកសារយោងដំបូងបង្អស់ចំពោះពិការភាពបានរកឃើញក្នុងច្បាប់ស្តីពីការអប់រំឆ្នាំ២០០៧ និងឯកសារពិគ្រោះចុងក្រោយបង្អស់ គឺគោលនយោបាយ ស្តីពីការអប់រំបរិយាបន្នឆ្នាំ២០១៨។ ច្បាប់ស្តីពីការអប់រំឆ្នាំ២០០៧ បានអនុម័តយកមកប្រើប្រាស់ភាគច្រើនគឺគំរូវេជ្ជសាស្ត្រនៃពិការភាព និងប្រើពាក្យ ***"ជនពិការ" "disabled"***។ ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការឆ្នាំ២០០៩ បានរក្សាទិដ្ឋភាពមួយចំនួននៃគំរូសុខាភិបាល ប៉ុន្តែផ្លាស់ប្តូរទៅជាវាក្យស័ព្ទបរិយាបន្នច្រើនជាង។ គោលនយោបាយស្តីពីការអប់រំបរិយាបន្នឆ្នាំ២០១៨ បន្សីកាន់តែជិតនឹងគំរូសុខាភិបាល ទទួលស្គាល់លក្ខខណ្ឌរូបវន្តរាំងស្ទះដល់ការចូលរួម។ គោលនយោបាយភាគច្រើនបង្ហាញពីចំណុចសំខាន់ៗ អំពីសិទ្ធិចំពោះការអប់រំសម្រាប់កុមារមានពិការភាព ក៏ប៉ុន្តែកាន់តែតិចទៅៗនិយាយដល់សិទ្ធិចំពោះការមិនរើសអើង និងការការពារប្រឆាំងនឹងអំពើហិង្សា។ បន្ថែមពីនេះ សិទ្ធិចំពោះការមិនរើសអើងត្រូវបានគិតគូរកាន់តែតិចទៅៗ ក្នុងគោលនយោបាយនានា។ ដូច្នេះគួរតែពិចារណាក្នុងការគិតគូរយកចិត្តទុកដាក់ដល់សិទ្ធិចំពោះការមិនរើសអើងដែលស្ថិតក្នុងគោលនយោបាយផ្សេងៗ យុទ្ធសាស្ត្រនានា និងសកម្មភាពអាទិភាពគន្លឹះទាំងឡាយអាចត្រូវបានរៀបចំធ្វើផែនការ និងអនុវត្តប្រកបដោយប្រសិទ្ធភាព។

គោលនយោបាយមួយចំនួនប្រើពាក្យ ភាសារើសអើង ឬមើលងាយដូចជា ***"អ្នកសិក្សាពិការ" "disabled learners"*** នឹងស្នើឱ្យមានថ្នាក់រៀនដាច់ដោយឡែកពីគ្នា ផ្ទុយនឹងគោលការណ៍នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ។ ទោះបីជាយ៉ាងណាក្តី កង្វះខាតយន្តការជាក់លាក់នានាក្នុងការជំរុញការអនុវត្តការមិនរើសអើង និងការទប់ស្កាត់អំពើហិង្សាបណ្តាលឱ្យកើតមានការអនុវត្តគោលនយោបាយ និងសេចក្តីណែនាំផ្សេងៗពុំមានប្រសិទ្ធភាព។ ទោះបីជា កើតមានបញ្ហាទាំងនេះ ប្រទេសកម្ពុជាបានបង្ហាញនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការគិតគូរការអប់រំបរិយាបន្នតាមរយៈការបង្កើតច្បាប់ គោលនយោបាយ និងក្របខណ្ឌគតិយុត្តនានាសម្រាប់ជនមានពិការភាព និងគ្រួសារនៃកុមារមានពិការភាព ដោយបានទទួលស្គាល់ គាំទ្រ និងនាំយកកុមារមានពិការភាពទៅសាលារៀន

អប់រំពិសេស។ កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកម្ពុជាក្នុងការធ្វើឱ្យល្អប្រសើរឡើងការអប់រំបរិយាបន្នតាមរយៈគោលនយោបាយជាច្រើនបង្ហាញពីឥរិយាបថផ្លាស់ប្តូរចំពោះពិការភាព។ លើសពីនេះទៅទៀត ការបន្ស៊ីគ្នាបន្ថែមទៀតជាមួយអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងគំរូសង្គមនៃពិការភាពគឺជាការចាំបាច់។ គោលនយោបាយដែលមានស្រាប់នានាក្នុងប្រទេសកម្ពុជា បានគូសបញ្ជាក់អំពីការផ្តល់ការអប់រំផ្សេងៗដល់កុមារមានពិការភាព ក៏ប៉ុន្តែមិនទាន់បានបន្ស៊ីគ្នាទាំងអស់ជាមួយគោលការណ៍សមាហរណកម្មឡើយ។ ក្នុងលក្ខណៈនេះ ការពិនិត្យ និងការកែសម្រួលគោលនយោបាយដែលមានស្រាប់ ដើម្បីបន្ស៊ីគ្នានឹងសមាហរណកម្ម និងចៀសវាងការនៅដាច់ដោយឡែកពីគ្នាពិតជាត្រូវការចាំបាច់ណាស់។ យន្តការនានាកាន់តែខ្លាំងគួរត្រូវបានបង្កើតឡើង និងទាមទារ ឱ្យមានគណនេយ្យភាព និងជំរុញការអនុវត្តគោលនយោបាយជាធរមាន។

## *សិទ្ធិចំពោះការអប់រំបរិយាបន្ន*

ការអប់រំបរិយាបន្នមានឫសគល់នៅក្នុងបញ្ញត្តិនៃសិទ្ធិមនុស្ស ដូចបានបង្ហាញដោយអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារឆ្នាំ១៩៨៩ និងសិទ្ធិជនមានពិការភាពឆ្នាំ២០០៦។ ទោះបីមានប្រទេសជាច្រើនបានផ្តល់សច្ចាប័នលើអនុសញ្ញាទាំងនេះក្តីមានប្រទេសមួយចំនួនតូចប៉ុណ្ណោះ បានដាក់បញ្ចូលអនុសញ្ញាទាំងនោះនៅក្នុងច្បាប់ជាតិរបស់ខ្លួន ដើម្បីធានាថាសិទ្ធិពលរដ្ឋត្រូវបានការពារ ជាពិសេសអ្នកងាយរងគ្រោះបំផុតក្នុងសង្គម ដូចជា កុមារ និងជនមានពិការភាពទាំងឡាយ។ ជាលទ្ធផល កុមារមានពិការភាពត្រូវបានគេមិនសូវបង្ហាញនៅក្នុងប្រព័ន្ធអប់រំឡើយ។ កុមារទាំងនោះភាគច្រើនបានចូលសាលារៀនតែមិនត្រូវបានគាំទ្រ ពេញលេញចំពោះតម្រូវការរៀនសូត្ររបស់គេ ឬត្រូវទទួលសេវាអប់រំមានគុណភាពទាប រួមទាំងដាក់ឱ្យរៀនដាច់ដោយឡែក ឬទទួលការអប់រំពិសេស ***"សិទ្ធិចំពោះការអប់រំមិនយកទៅប្រើក្នុងបរិយាបន្នដោយស្វ័យប្រវត្តិនោះទេ"***។ សិទ្ធិចំពោះការអប់រំនៅក្នុងប្រព័ន្ធអប់រំទូទៅ និងការទប់ស្កាត់ការអនុវត្តការរើសអើង ត្រូវបានបង្ហាញច្បាស់លើកដំបូងនៅក្នុងឧបករណ៍លម្អិតបន្ថែមទៀតដូចជា សេចក្តីប្រកាសចមធានឆ្នាំ១៩៩០ (Jomtien Declaration) និងត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសេចក្តីថ្លែងការណ៍សាឡាម៉ាន់កា (Salamanca Statement) រៀបចំដោយអង្គការយូនីស្កូឆ្នាំ១៩៩៤ (UNESCO) និងក្របខណ្ឌពាក់ព័ន្ធសម្រាប់ការអនុវត្ត។ សិទ្ធិនេះបានស្នើការផ្លាស់ប្តូរគោលនយោបាយតម្រូវរួមបញ្ចូលកុមារមានតម្រូវការអប់រំពិសេស។ ការប្តេជ្ញាចិត្តមួយត្រូវបានធ្វើឡើងដើម្បីជំរុញវិធីសាស្ត្រនៃការអប់រំបរិយាបន្ន។

> *សាលារៀនទូទៅជាមួយនឹងការតម្រង់ទិសបរិយាបន្ន គឺជាមធ្យោបាយប្រកបដោយប្រសិទ្ធភាពបំផុត ក្នុងការប្រយុទ្ធប្រឆាំងឥរិយាបថរើសអើង បង្កើតសហគមន៍ដែលស្វាគមន៍ កសាងសង្គមបរិយាបន្ន និងសម្រេចឱ្យបានការអប់រំសម្រាប់ទាំងអស់គ្នា។ ជាងនេះទៅទៀត សាលារៀនផ្តល់ការអប់រំប្រកបដោយបរិយាបន្ន ដល់កុមារភាគច្រើន និងកែលម្អប្រសិទ្ធភាព និងការចំណាយប្រកបដោយប្រសិទ្ធភាពយ៉ាងពិតប្រាកដនៃប្រព័ន្ធអប់រំទាំងមូល (UNESCO, 1994, Article 2)* ។

នាពេលថ្មីៗនេះ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព៤ (SDG 4) បានដៅយ៉ាងច្បាស់ ពីការឈានទៅរកការអប់រំបរិយាបន្នប្រកបដោយគុណភាព និងការសិក្សាពេញមួយជីវិតក្នុងបរិយាកាសសិក្សាដែលមានការគាំទ្រប្រកបដោយផាសុកភាព។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤បានកត់សម្គាល់ជាប្រភេទ នៃតម្រូវការ *"លុបបំបាត់ភាពខុសគ្នាខាងយេនឌ័រក្នុងការអប់រំ និងធានាដល់ការទទួលបានសេវាអប់រំស្មើគ្នានៅគ្រប់កម្រិតសិក្សា និងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ក្រុមងាយរងគ្រោះ រួមទាំងជនមានពិការភាព ជនជាតិដើមភាគតិច និងកុមារស្ថិតក្នុងស្ថានភាពងាយរងគ្រោះ"*

ក្នុងឆ្នាំ២០៣០ (Target 4.5)។ គោលដៅនេះ កំណត់ពីតម្រូវការកសាង និងកែលម្អសម្ភារូបវន្ត ឆ្លើយតបនឹងការអប់រំកុមារមាននិងមិនមានពិការភាព និងយេនឌ័រត្រូវបានយកចិត្តទុកដាក់ និងផ្ដល់សុវត្ថិភាព បរិយាកាសបែបបរិយាបន្នគ្មានហិង្សាសម្រាប់ទាំងអស់គ្នា (Target 4.A)។

*ម្យ៉ាងវិញទៀត អង្គការយូនីសេហ្វមានទស្សនៈវិស័យថា សកលលោកនឹងកាន់តែបរិយាបន្នឡើង ដល់ឆ្នាំ២០៣០*[2] ជាកន្លែងដែលកុមារទាំងអស់រួមទាំងកុមារមានពិការភាពដែលរស់នៅក្នុងសហគមន៍មួយមិនមានឧបសគ្គ និងប្រកបដោយបរិយាបន្ន។ គោលនយោបាយស្ដីពីការអប់រំបរិយាបន្នសម្រាប់ពិការភាព និងបានដាក់ចេញយុទ្ធសាស្ត្រជាអាទិភាពចំនួន៦៖ កិច្ចការពារពីការមើលងាយ និងការរើសអើង។ ការកែលម្អសេវាបរិយាបន្នផ្នែកពិការភាព ទីកន្លែងការងារ និងកម្មវិធីផ្សេងៗ។ ការទទួលបានសេវាការថែទាំតាមសហគមន៍បានទូលំទូលាយ និងសេវាគាំទ្រសមស្រប។ ការទទួលបានសេវាបច្ចេកវិទ្យាជំនួយ។ សកម្មភាពបរិយាបន្នផ្នែកពិការភាពមនុស្សជាតិ ការសង្គ្រោះគ្រោះមហន្តរាយ និងតំបន់ងាយរងគ្រោះ។ ការចូលរួមពេញលេញរបស់ជនមានពិការភាព។ គោលនយោបាយស្ដីពីការអប់រំបរិយាបន្នផ្នែកពិការភាព គឺជាផែនទីបង្ហាញផ្លូវសម្រាប់ការសម្របសម្រួលអន្តរវិស័យ ដើម្បីធ្វើបរិយាបន្នផ្នែកពិការភាពនៅតាមអង្គភាពគ្រប់កម្រិត ឆ្លើយតបទៅនឹងតម្រូវការរបស់កុមារមានពិការភាពចំនួន២៤០លាននាក់ លើពិភពលោក។

ជារួមយុទ្ធសាស្ត្រទាំង៦ *ជាការរំពឹកនៃភាពបន្ទាន់ក្នុងការអំពាវនាវដល់ប្រទេសទាំងឡាយ ឱ្យធានានូវការអប់រំប្រកបដោយបរិយាបន្ន សមធម៌ និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា*[3]។ ចំណុចខ្លះមានលក្ខណៈត្រូវគ្នានឹងវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សចំពោះការអប់រំ និងការផ្លាស់ប្ដូរពីសាលាអប់រំពិសេស អប់រំដាច់ដោយឡែក សម្រាប់កុមារមានពិការភាព ទទួលបានការអប់រំសម្រាប់កុមារទាំងអស់ក្នុងក្របខណ្ឌទូទៅ។

## ១.២ បរិបទប្រទេស

រាជរដ្ឋាភិបាលកម្ពុជានៃព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសហត្ថលេខីនៃសន្ធិសញ្ញាស្ដីពីសិទ្ធិមនុស្ស ពិធីសារ និងក្របខណ្ឌគតិយុត្តពាក់ព័ន្ធនឹងសិទ្ធិមនុស្សសំខាន់ៗទាំងអស់របស់អង្គការសហប្រជាជាតិ។ រាជរដ្ឋាភិបាលបានគាំទ្រសេចក្ដីថ្លែងការណ៍សាឡាម៉ាន់កា ស្ដីពីការអប់រំនៃតម្រូវការពិសេសឆ្នាំ១៩៩៤ (1994 Salamanca Statement on Special Needs Education) ក្របខណ្ឌសហសវត្សរ៍ប៊ីវ៉ាកូ សម្រាប់សកម្មភាពឆ្នាំ២០០៣ (Biwako Millennium Framework for Action) និងអនុសញ្ញាស្ដីពីការលើកកម្ពស់សិទ្ធិនៃជនពិការ ទីក្រុងបាងកក ឆ្នាំ២០០៦ (Bangkok Convention on the Promotion of the Rights of People with Disabilities)។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ និងគោរពសិទ្ធិមនុស្សជាមូលដ្ឋាន និងសេចក្ដីថ្លៃថ្នូរនៃជនមានពិការភាព។ យោងតាមមាត្រា៧៤នៃរដ្ឋធម្មនុញ្ញបានអះអាងថា *"រដ្ឋជួយឧបត្ថម្ភជនពិការ និងដល់គ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រទេសជាតិ"*។ បន្ថែមពីនេះ ច្បាប់ស្ដីពីការអប់រំ មាត្រា៧ មាត្រា៣៨ និងមាត្រា៣៩បានបញ្ជាក់អំពីការអប់រំពិសេស ជាពិសេស ពាក់ព័ន្ធនឹងសិទ្ធិនៃអ្នកសិក្សាមានពិការភាពសិក្សាជាមួយអ្នកសិក្សាមិនមានពិការភាព និងផ្ដល់សេវាអប់រំពិសេសដល់អ្នកសិក្សាមានពិការភាព។

---

[2] *United Nations Children's Fund, Disability Inclusion Policy and Strategies (DIPAS) 2022-2030, UNICEF, February 2023, <www.unicef.org/unicef-disability-inclusion-policy-and-strategy-dipas-2022-2030>.*

[3] *United Nations Sustainable Development Goals, Goal 4: Quality Education , <https://unstats.un.org/sdgs/report/2017/goal-04/>.*

រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងយកចិត្តទុកដាក់អនុវត្តច្បាប់អន្តរជាតិ ជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារពាក់ព័ន្ធ ដើម្បីឆ្លើយតបនឹងតម្រូវការកុមារ និងការការពារ ឬគាំពារពិសេសរបស់ពួកគេ ព្រមទាំងបានដាក់ចេញនូវវិធានការជាច្រើន ដើម្បីធានាសុខុមាលភាព និងគាំពារសង្គមនៃកុមារ។ ក្នុងពេលជាមួយគ្នានេះដែរ កម្ពុជាបានចេញច្បាប់ គោលនយោបាយ និងផែនការសកម្មភាពជាតិព្រមទាំងក្របខណ្ឌគោលនយោបាយជាតិសម្រាប់គាំពារសង្គម ឆ្នាំ២០១៦-២០២៥ គោលនយោបាយជាតិស្តីពីការគាំពារកុមារ ២០១៩-២០២៩។ គោលនយោបាយ ស្តីពីការថែទាំជំនួសកុមារ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន(Law on Juvenile Justice) ច្បាប់អន្តរជាតិស្តីពីការសុំកូន និងក្របខណ្ឌគតិយុត្តដទៃទៀត ដើម្បីផ្តល់ផលប្រយោជន៍សម្រាប់កុមារនូវសិទ្ធិជាមូលដ្ឋាននៅក្នុងមជ្ឈមណ្ឌល និងសហគមន៍។

គោលនយោបាយ ស្តីពីការអប់រំបរិយាបន្នឆ្នាំ២០១៨ មានចក្ខុវិស័យ ដើម្បីធានានូវការគោរពសិទ្ធិជនមានតម្រូវការពិសេស សិទ្ធិទទួលបានការអប់រំ ប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន និងការសិក្សាពេញមួយជីវិត។ បន្ទាប់មកផែនការសកម្មភាព ស្តីពីការអប់រំបរិយាបន្នរយៈពេល៥ឆ្នាំដំបូង ត្រូវបានបង្កើតឡើងឆ្នាំ២០១៩-២០២៣នឹងផ្តល់ការអនុវត្តច្បាស់លាស់ដល់អ្នកពាក់ព័ន្ធ ដើម្បីកែទម្រង់ជាប្រព័ន្ធ។ ផែនការសកម្មភាព ស្តីពីការអប់រំបរិយាបន្នជាមាគ៌ាដ៏សំខាន់មួយសម្រាប់ការអនុវត្តការអប់រំបរិយាបន្ននៅកម្ពុជា នៅក្នុងនោះមានសូចនាករសំខាន់ៗ ដូចជាក្រុមគោលដៅ ពេលវេលានៃការអនុវត្ត ការទទួលខុសត្រូវ និងការគាំទ្រពីស្ថាប័នធនធានថវិកា ការត្រួតពិនិត្យ និងវាយតម្លៃ។ ផែនការសកម្មភាពនេះត្រូវបានរំពឹងទុកថា លទ្ធផលការចុះឈ្មោះចូលរៀនរបស់ជនដែលមានតម្រូវការពិសេសនឹងមានការកើនឡើង តាមរយៈសកម្មភាពលើកកម្ពស់ការយល់ដឹងនៅក្នុងសហគមន៍ និងការកំណត់អត្តសញ្ញាណ ជនដែលមានតម្រូវការពិសេស ( ទាំងក្នុង និងក្រៅសាលា) ដោយផ្តល់ការគាំទ្រចាំបាច់ និងពង្រឹងសមត្ថភាព តាមស្ថាប័ន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ជនដែលមានតម្រូវការពិសេស មានការបណ្តុះបណ្តាលគ្រូ ការបង្កើតសេវាអប់រំ ការអភិវឌ្ឍវិធីសាស្ត្របង្រៀន និងកម្មវិធីសិក្សាឱ្យបានសមស្រប។ យុទ្ធសាស្ត្រទាំង៨រួមមាន៖ ការអភិវឌ្ឍក្របខណ្ឌច្បាប់ និងយន្តការ កិច្ចសហការអន្តរក្រសួងក្នុងការកំណត់អត្តសញ្ញាណបឋម អភិវឌ្ឍប្រព័ន្ធប្រមូលទិន្នន័យព័ត៌មាន ផ្តល់ការអប់រំមានគុណភាពប្រកបដោយបរិយាបន្ន និងសមធម៌ ធានាឱកាសអប់រំប្រកបដោយគុណភាព សមភាព សមធម៌សម្រាប់សិស្សស្រីស្ថិតក្នុងសេចក្តីត្រូវការពិសេស អភិវឌ្ឍគំរូស្តង់ដាជាសកល សម្រាប់ការសាងសង់អគារសិក្សា និងអនាម័យទឹកស្អាត ការកសាងសមត្ថភាពគ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន និងលើកកម្ពស់គោលនយោបាយ ស្តីពីការអប់រំបរិយាបន្ន។

លទ្ធផលទទួលបានពីការអនុវត្តផែនការសកម្មភាព២០១៩-២០២៣ មេរៀនបទពិសោធន៍ និងបញ្ហាប្រឈមនានា ត្រូវបានពិភាក្សាគ្នានៅផ្នែកខាងក្រោម។ ផែនការសកម្មភាព២០២៤-២០២៨ ត្រូវបានបង្កើតឡើង ដើម្បីពង្រឹង និងធ្វើឱ្យសម្រេចបាននូវអាទិភាពសំខាន់ៗ ឱ្យឆ្លើយតបទៅនឹងបញ្ហាប្រឈមនានាតាមរយៈការសង្កេត ក្នុងអំឡុងពេលអនុវត្តផែនការសកម្មភាព ស្តីពីការអប់រំបរិយាបន្នដំបូង។

### ១.៣ សមិទ្ធផលសំខាន់ៗនៃផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន ២០១៩-២០២៣

ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តគោលនយោបាយស្តីពីការអប់រំបរិយាបន្ន នៅឆ្នាំ២០១៨ និងផែនការសកម្មភាព ស្តីពីការអប់រំបរិយាបន្ន២០១៩-២០២៣ នៅឆ្នាំ២០១៩ ដែលរួមបញ្ចូលយុទ្ធសាស្ត្រ និងសកម្មភាពអាទិភាពគន្លឹះនានា ដើម្បីពង្រីកការទទួលបានការអប់រំបរិយាបន្នប្រកបដោយគុណភាពសម្រាប់កុមារ

មានពិការភាព។ កិច្ចខិតខំប្រឹងប្រែងទាំងឡាយត្រូវបានធ្វើឡើងតាមរយៈការបង្កើតគោលនយោបាយ ការពង្រឹងសមត្ថភាព ស្ថាប័ន និងការផ្តល់អន្តរាគមន៍ផ្សេងៗដល់កុមារមានពិការភាព។ នាយកដ្ឋានអប់រំពិសេសនៃក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានជាតិអប់រំពិសេសក៏ត្រូវបានបង្កើតឡើង និងដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលសេវាអប់រំបរិយាបន្ន អភិវឌ្ឍកម្មវិធីសិក្សាដល់គ្រូបង្រៀនរួមទាំងផ្តល់ការបណ្តុះបណ្តាលសម្រាប់គ្រូបង្រៀន និងកិច្ចសហប្រតិបត្តិការជាមួយវិទ្យាល័យអប់រំពិសេស ថ្នាក់សមាហរណកម្ម និងសាលារៀនអប់រំបរិយាបន្នក្នុងការបង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់កុមារមានពិការភាព។

ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើរបាយការណ៍អំពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់នៃការបណ្តុះបណ្តាលគ្រូអំពីការអប់រំបរិយាបន្ន។ វឌ្ឍនភាពនេះសម្រេចបានតាមរយៈការដាក់បញ្ចូលការអប់រំបរិយាបន្នទៅក្នុងកម្មវិធីសិក្សាបណ្តុះបណ្តាលគ្រូដំបូង ដែលត្រូវបានអនុវត្តនៅវិទ្យាស្ថានបណ្តុះបណ្តាលគ្រូ ឬសាលាគរុកោសល្យ និងវិក្រឹតការទូទាំងប្រទេស រួមទាំងមជ្ឈមណ្ឌលបណ្តុះបណ្តាលដំបូង និងវិក្រឹតការ និងវិទ្យាស្ថានជាតិអប់រំផងដែរ។ ជាងនេះទៅទៀត វគ្គសិក្សាឯកទេសកម្រិតសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ត្រូវបានបង្កើតឡើងក្នុងជំនាញឯកទេសបីប្រភេទ និងបានបណ្តុះបណ្តាលគ្រូឯកទេសចំនួន១២០នាក់ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ។ គ្រូបង្រៀនទាំងនេះត្រូវបានដាក់ឱ្យបម្រើការ ដើម្បីគាំទ្រការសិក្សារបស់កុមារមានពិការភាពជាសំខាន់ក្នុងវិទ្យាល័យអប់រំពិសេសចំនួន៦។ បន្ថែមពីនេះ ការបណ្តុះបណ្តាលវិក្រឹតការត្រូវបានផ្តល់ប្រមាណ៤០០០នាក់ និងបុគ្គលិកអប់រំពីក្រសួងអប់រំ យុវជន និងកីឡា និងតាមបណ្តាសាលារៀននានា។

សម្រាប់ឆ្នាំសិក្សា២០២២-២០២៣ សិស្សមានពិការភាពប្រមាណ១៦.១៣២នាក់ ក្នុងនោះសិស្សស្រីមានពិការភាពចំនួន៥២៥៤នាក់បានចុះឈ្មោះចូលរៀនតាមសាលារៀននានាទូទាំងប្រទេស។ សាលារៀនទាំងនេះរួមមានសាលារៀនទូទៅ ថ្នាក់សមាហរណកម្ម និងវិទ្យាល័យអប់រំពិសេស។ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កលក្ខណៈងាយស្រួលដល់ការប្រតិបត្តិ ចំពោះវិទ្យាល័យអប់រំពិសេសចំនួន៦។ វិទ្យាល័យអប់រំពិសេសទាំងនេះមានសិស្សចូលរៀនចំនួន១០៧៥នាក់ ក្នុងនោះសិស្សស្រីចំនួន១៥៦នាក់ ដែលមានពិការភាពកម្រិតមធ្យម និងធ្ងន់ធ្ងរ។ លើសពីនេះទៀត ក្រសួងអប់រំ យុវជន និងកីឡាបានទទួលយកបណ្តើរៗថ្នាក់សមាហរណកម្មចំនួន៣១ដែលពីមុនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ដៃគូអភិវឌ្ឍន៍។

ភាពជាដៃគូជាមួយអង្គការក្រៅរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ រួមទាំងអង្គការយូនីសេហ្វ បានផ្តល់ផាសុកវត្ថុ ដើម្បីគាំទ្រដល់កុមារមានពិការភាពឱ្យទទួលបានសេវាចាំបាច់ និងកម្មវិធីសិក្សាតាមផ្ទះត្រូវបានផ្តល់ជូនក្នុងរយៈពេល៥ឆ្នាំចុងក្រោយ។ ព័ត៌មានពិស្តារអំពីកិច្ចការងារនេះត្រូវបានសម្រេចដោយនាយកដ្ឋានអប់រំពិសេស។

ការអនុវត្តផែនការសកម្មភាពអស់រយៈពេល៥ឆ្នាំកន្លងមក កម្មវិធីកសាងសមត្ថភាពជាច្រើនត្រូវបានធ្វើឡើង ឯកសារបង្រៀនមួយចំនួនត្រូវបានចងក្រង និងកិច្ចប្រជុំជាច្រើនត្រូវបានរៀបចំឡើង ដើម្បីកែលម្អគុណភាពបង្រៀន ការផ្តល់សេវាផ្សេងៗ ការកំណត់អត្តសញ្ញាណកុមារមានពិការភាព ការសម្របសម្រួល និងការជួយសម្រួលឱ្យកាន់តែល្អប្រសើរឡើងក្នុងចំណោមអ្នកពាក់ព័ន្ធ ព្រមទាំងសកម្មភាពផ្សេងៗ។ ខណៈដែលលទ្ធផលល្អមួយចំនួនសម្រេចបានយ៉ាងណាក៏ដោយ ប៉ុន្តែក៏នៅមានតម្រូវការមួយចំនួនតូចមិនទាន់បានឆ្លើយតបទៅនឹងយុទ្ធសាស្រ្តចម្បងៗ និងសកម្មភាពអាទិភាពមានដូចជា៖ កង្វះការគាំទ្រ ផ្នែកសម្ភារៈហិរញ្ញវត្ថុ កិច្ចសហការ និងកិច្ចសហប្រតិបត្តិការ ពីកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ក្រៅពីលទ្ធផលសម្រេចបានទាំងអស់នេះ ការផ្សព្វផ្សាយគោលនយោបាយ និងក្របខណ្ឌគតិយុត្តរួមទាំង ការបង្រៀនចង្អុលបង្ហាញ គោលការណ៍ណែនាំ និងការយល់ដឹងអំពីឯកសារទាំងអស់នេះចាំបាច់កែលម្អ និងអភិវឌ្ឍឡើងថែមទៀត។ គេរកឃើញផងដែរនូវការលំបាកផ្សេងៗ និងបញ្ហាប្រឈមនានាដែលកុមារមានពិការភាពធ្ងន់ធ្ងរនៅក្រៅសាលារៀនមិនទាន់បានទទួលសេវាអប់រំ ការថែទាំសុខភាព និងការស្តារនីតិសម្បទានៅឡើយ។ ការផ្សព្វផ្សាយនិងការយល់ដឹងអំពីពិការភាពនៅកម្រិតសហគមន៍ក៏នៅមិនទាន់បានទូលំទូលាយផងដែរ។ ការផ្តល់សេវាស្តារនីតិសម្បទាមិនទាន់បានឆ្លើយតបនឹងតម្រូវការរបស់កុមារមានពិការភាពនៅឡើយ។ ដូច្នេះនៅមានកិច្ចខិតខំប្រឹងប្រែងសំខាន់ៗជាច្រើនទៀតដែលត្រូវបន្តធ្វើ ដូចជា៖ ការបោះពុម្ពឯកសារអក្សរស្ទាប និងភាសាសញ្ញា វចនានុក្រមរូបភាព ការកំណត់អត្តសញ្ញាណកុមារមានពិការភាពក្នុងបណ្តារាជធានីខេត្តគោលដៅ ការផ្សព្វផ្សាយឧបករណ៍កំណត់អត្តសញ្ញាណ ការផ្តល់កម្មវិធី និងការផ្តល់វគ្គបណ្តុះបណ្តាល និងកម្មវិធីកសាងសមត្ថភាពទៀងទាត់បន្ថែមទៀត  ព្រមទាំងវគ្គសិក្សាខ្លីៗ សម្រាប់គ្រូបង្រៀន និងគណៈកម្មការគ្រប់គ្រងសាលារៀន។ លើសពីនេះទៅទៀតវគ្គវិក្រឹតការសម្រាប់គ្រូបង្រៀន និងបុគ្គលិកជំនាញអប់រំពិសេស ការពិនិត្យតាមដាន និងវាយតម្លៃលើផែនការសកម្មភាព ស្តីពីការអប់រំបរិយាបន្នឱ្យបានត្រឹមត្រូវ  ជំរុញកិច្ចសហប្រតិបត្តិការ និងកិច្ចសហការជិតស្និទ្ធរវាងស្ថាប័នរដ្ឋ(អន្តរក្រសួង) ជាមួយដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិ (ពិការភាព) អាជ្ញាធរមូលដ្ឋាន សាលារៀន ឪពុកម្តាយ សហគមន៍ និងសាធារណជនទូទៅ។

## បញ្ហាប្រឈមក្នុងការអនុវត្តផែនការសកម្មភាពអប់រំបរិយាបន្នឆ្នាំ ២០១៩-២០២៣

ឧបសគ្គមួយក្នុងចំណោមឧបសគ្គធំៗចំពោះការអនុវត្តផែនការសកម្មភាពការអប់រំបរិយាបន្ន ខ្វះខាតការគាំទ្រផ្នែកថវិកាក្នុងការអនុវត្តផែនការសកម្មភាព។ របាយការណ៍ស្តីពីការពិនិត្យតាមដាន និងការវាយតម្លៃមិនទាន់ត្រូវបានរៀបចំឡើងពេញលេញ។ ក្រសួងអប់រំ យុវជន និងកីឡាក៏មិនមានរបាយការណ៍វាយតម្លៃស៊ីជម្រៅមួយអំពីលទ្ធផលសម្រេចបាននៃការអនុវត្តផែនការសកម្មភាពនោះទេ។ នេះជាមេរៀនបទពិសោធន៍មួយសម្រាប់ការអនុវត្តផែនការសកម្មភាព ស្តីពីការអប់រំបរិយាបន្នសម្រាប់ប្រាំឆ្នាំបន្ទាប់។

បើធៀបទៅនឹងកុមារផ្សេងទៀត កុមារមានពិការភាពហាក់ដូចជាពុំសូវបានចូលរៀន ឬនៅក្រៅសាលារៀនតែម្តង។ ការអប់រំបរិយាបន្ន គឺជាវិធីសាស្ត្រមួយដែលអាចកែប្រែ ឬផ្លាស់ប្តូរប្រព័ន្ធអប់រំ រួមទាំងរចនាសម្ព័ន្ធគោលនយោបាយ ការអនុវត្ត និងធនធានមនុស្ស ដោយបង្កលក្ខណៈងាយស្រួលដល់អ្នកសិក្សាទាំងអស់។ ដើម្បីធានានូវការគោរពសិទ្ធិក្នុងការអប់រំ យន្តការផ្សេងៗចាំបាច់ត្រូវអនុវត្តសម្រាប់សាលារៀន គ្រូបង្រៀន គ្រួសារ និងសិស្ស ដើម្បីលុបបំបាត់នូវការរើសអើង លើសពីនេះតម្រូវឱ្យខិតខំប្រឹងប្រែងអប់រំផ្សព្វផ្សាយដល់សហគមន៍អំពីតម្រូវការ និងសិទ្ធិរបស់សមាជិកសហគមន៍ដែលមានពិការភាពផងដែរ។ បេសកកម្មនៃការអប់រំបរិយាបន្ន គឺអំពីការកំណត់អត្តសញ្ញាណ និងការលុបបំបាត់នូវរនាំងឧបសគ្គនានាគ្រប់កម្រិត។ ក្នុងពេលអនុវត្តផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន ឆ្នាំ២០១៩-២០២៣ អ្វីដែលបានរកឃើញកង្វះខាតការគាំទ្រផ្នែកសម្ភារៈដល់កុមារមានតម្រូវការពិសេសនៅតំបន់ដាច់ស្រយ៉ាល កង្វះការយល់ដឹងអំពីផលប្រយោជន៍នៃការអប់រំបរិយាបន្ន និងឪពុកម្តាយដែលមានកូនមានពិការភាពខ្វះព័ត៌មាន ពាក់ព័ន្ធនឹងសាលារៀនអប់រំពិសេស និង

ថ្នាក់សមាហរណកម្មនៅក្នុងរាជធានី ខេត្តដែលពួកគាត់រស់នៅ។ ការព្រួយបារម្ភគឺនៅតែមានពីឪពុកម្តាយចំពោះការបញ្ជូនកូនមានពិការភាពរបស់ខ្លួនទៅសាលារៀន និងរស់នៅដាច់ឆ្ងាយពីគ្រួសាររបស់ពួកគាត់។

## ២. ការវិភាគស្ថានភាពអំពីកុមារមានពិការភាព

### ២.១. ការវិភាគស្ថានភាពអំពីការអប់រំបរិយាបន្ននៅក្នុងប្រទេសកម្ពុជា

ក្រៅពីការងារជោគជ័យលើកិច្ចខិតខំប្រឹងប្រែងការអប់រំបរិយាបន្ននៅកម្ពុជា បញ្ហាប្រឈមក៏នៅតែកើតមានដូចជា៖ កង្វះជំនាញបច្ចេកទេសអប់រំពិសេស គ្រូបង្រៀន សម្ភារបង្រៀន និងរៀន សេវាគាំទ្រ ផ្នែកថវិកា និងបញ្ហាផ្សេងៗទៀតសុទ្ធតែជាឧបសគ្គដ៏សំខាន់ក្នុងការពង្រឹងលើសេចក្តីណែនាំ លិខិតបទដ្ឋាន និងផែនការសកម្មភាព ស្តីពីការអប់រំបរិយាបន្ន។ លើសពីនេះ អ្វីដែលត្រូវយកចិត្តទុកដាក់គឺការគាំទ្រពីក្រុមគ្រួសារដែលមានកូនមានពិការភាព ហើយបញ្ជូនទៅសាលារៀន (កង្វល់លើបញ្ហាលំបាក និងការរើសអើងនៅសាលារៀន)។ ទន្ទឹមគ្នានេះដែរ ការគាំទ្រពីសហគមន៍នៅតែត្រូវការការកែលម្អ កង្វះគ្រូបង្រៀនទាំងនៅសាលារដ្ឋ និងសាលាឯកជនដែលមានសិស្សមានពិការភាពរៀនក៏នៅតែត្រូវយកចិត្តទុកដាក់ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈម។

ច្បាប់ និងគោលនយោបាយជះឥទ្ធិពលលើការវិភាគពាក់ព័ន្ធការអប់រំបរិយាបន្ន និងការអប់រំពិសេស គឺមានសារៈសំខាន់ណាស់ដល់ភាគីពាក់ព័ន្ធ ជាពិសេស ពីសាលារៀន ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការអភិវឌ្ឍផែនការសកម្មភាពជាតិជាក់ស្តែង។

ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការអនុវត្ត ការអប់រំបរិយាបន្នត្រូវបានលើកកម្ពស់ និងអភិវឌ្ឍ ការអប់រំពិសេស និងការអប់រំថ្នាក់សមាហរណកម្មនៅមានកម្រិតនៅឡើយ និងពុំទាន់បានឆ្លើយតបតាមតម្រូវការ ជាពិសេសនៅក្នុងតំបន់ជនបទ និងតំបន់ដាច់ស្រយ៉ាល។ កង្វះការគាំទ្រផ្នែកថវិកាក្នុងការអនុវត្តផែនការ និងមានវិសាលភាព និងការលើកទឹកចិត្តដល់គ្រួសារដែលមានកូនមានពិការភាពក៏នៅតែជាបញ្ហាព្រួយបារម្ភនៅឡើយ។

### ២.២. បញ្ហាប្រឈម និងរនាំងឧបសគ្គចំពោះការអប់រំបរិយាបន្ន

នៅក្នុងប្រទេសកម្ពុជា អនុសញ្ញាស្តីពីសិទ្ធិជនពិការត្រូវបានផ្តល់សច្ចាប័ន គោលនយោបាយស្តីពីការអប់រំកុមារពិការ គោលនយោបាយស្តីពីការអប់រំបរិយាបន្ន និងផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន ត្រូវបានអនុវត្ត ដើម្បីធានាថាមនុស្សគ្រប់រូបទទួលបានការអប់រំដូចគ្នា។ ជាងនេះទៅទៀត បញ្ហាប្រឈមជាច្រើននៅតែបន្តកើតមាន ដូចជារនាំងឧបសគ្គចំពោះការទទួលបានការអប់រំពីព្រោះតែភាពក្រីក្រ ឥរិយាបថមិនសមរម្យ និងការយល់ដឹងមានកម្រិតអំពីពិការភាពជាដើម។ បញ្ហានេះបានបណ្តាលឱ្យមានគម្លាតគ្នារវាងគោលនយោបាយ និងច្បាប់ដែលមានស្រាប់ និងការអនុវត្តនៅក្នុងថ្នាក់រៀន និងកម្រិតសាលារៀន។

ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ ត្រូវការការយល់ដឹងឱ្យបានល្អប្រសើរ លើបញ្ហាប្រឈមក្នុងការអនុវត្តការអប់រំបរិយាបន្ននៅកម្ពុជា គំនិតផ្តួចផ្តើមថ្មី ស្តីពីការសិក្សាសម្រាប់ទាំងអស់គ្នា បានអប់រំផ្សព្វផ្សាយ តាមរយៈភាពជាដៃគូ រវាងយូនីសេហ្វ អ៊ីណូសិនទី (UNICEF Innocenti ) យូនីសេហ្វកម្ពុជា (UNICEF Cambodia) យូនីសេហ្វអាស៊ីបូព៌ា (UNICEF East Asia) និងការិយាល័យប្រចាំតំបន់ប៉ាស៊ីហ្វិក (Pacific Regional Office) និងក្រសួងអប់រំ

យុវជន និងកីឡា។ *វិធីសាស្ត្រស្រាវជ្រាវត្រូវបានបង្កើតឡើងចេញពីការបោះពុម្ពផ្សាយលើកទី៣នៃគោលវិធីវិភាគតាមវិស័យអប់រំ* [4] (Education Sector Analysis Methodological Guidelines) (UNESCO-IIEP, UNICEF, GPE, and FCDO, 2021 និង បានដាក់ឱ្យប្រើប្រាស់វិធីសាស្ត្រចម្រុះមួយ រួមទាំងការវិភាគគោលនយោបាយ និងទិដ្ឋភាព ការវិភាគទិន្នន័យមានស្រាប់ និងការស្រាវជ្រាវស៊ីជម្រៅបឋម ដើម្បីស្វែងយល់អំពីកត្តាទាំងឡាយដែលជះឥទ្ធិពលលើការអនុវត្តការអប់រំបរិយាបន្នពីការផ្តល់សេវា ផ្នែកផ្គត់ផ្គង់ និងតម្រូវការ និងបរិយាកាសអំណោយផល។

ក្របខណ្ឌការអប់រំបរិយាបន្នសម្រាប់ពិការភាពត្រូវបានប្រើ ដើម្បីរៀបចំរចនាសម្ព័ន្ធនៃការវិភាគ និងផ្តល់ព័ត៌មានអំពីអនុសាសន៍នានា។ ក្របខណ្ឌនេះ គឺជាឧបករណ៍មួយដែលត្រូវបានប្រើក្នុងការត្រួតពិនិត្យប្រព័ន្ធអប់រំទាំងមូល តាមរយៈឧបករណ៍អប់រំបរិយាបន្នសម្រាប់ពិការភាព។ ក្របខណ្ឌនេះបានផ្តល់នូវវិធីមួយក្នុងការកំណត់អំពីតម្រូវការអ្វីដែលនឹងត្រូវបានដាក់នៅនឹងកន្លែង ដើម្បីធ្វើឱ្យប្រព័ន្ធអប់រំទាំងមូលមានលក្ខណៈជាការអប់រំបរិយាបន្នសម្រាប់ពិការភាព។ ក្នុងពេលដែលក្របខណ្ឌនេះផ្តោតលើកុមារមានពិការភាព គេរំពឹងថាការកែលម្អឱ្យប្រសើរឡើងនានាត្រូវបានកំណត់ឃើញនឹងផ្តល់អត្ថប្រយោជន៍ដល់ការចូលរួម និងលទ្ធផលសិក្សានៃកុមារគ្រប់រូបទាំងមានពិការភាព ឬមិនមានពិការភាព។ *(សូមមើលក្នុងឧបសម្ព័ន្ធ២៖ ក្របខណ្ឌអប់រំបរិយាបន្ន)។*

ការវិភាគធ្វើជាផ្នែកធំពីរ៖ ការផ្តល់សេវា (កម្រិតការអនុវត្ត) និងបរិយាកាសអំណោយផល (កម្រិតគោលនយោបាយ) *ដែលបានផ្តល់នូវទិដ្ឋភាពទូទៅអំពីអ្វី និងរបៀបដែលមជ្ឈដ្ឋានគោលនយោបាយបច្ចុប្បន្នគាំទ្រការអនុវត្តការអប់រំបរិយាបន្នសម្រាប់ពិការភាព។*

*របកគំហើញ និងអនុសាសន៍សំខាន់ៗ ដែលបានមកពីការវិភាគចេញពីការស្រាវជ្រាវនេះ ជាផែនទីបង្ហាញផ្លូវក្នុងដំណើរការនៃការជ្រើសរើសយុទ្ធសាស្ត្រ សម្រាប់ការបង្កើតផែនការសកម្មភាព ស្តីពីការអប់រំបរិយាបន្ន ២០២៤-២០២៨ ដើម្បីបរិវត្តន៍កម្មការអប់រំបរិយាបន្នប្រកបដោយគុណភាពសម្រាប់ទាំងអស់គ្នានៅកម្ពុជា។*

ការវិភាគ បានចាប់ផ្តើមជាមួយនឹងការពិនិត្យមើលយ៉ាងយកចិត្តទុកដាក់បំផុតនៃបរិយាកាសអំណោយផលដែលស្គាល់ថាជាប្រព័ន្ធក្របខណ្ឌមូលដ្ឋានដ៏សំខាន់ ក្នុងការអនុវត្តការអប់រំបរិយាបន្នសម្រាប់ពិការភាព។

***របកគំហើញទាំងនោះបង្ហាញជាក់ស្តែងថា៖***

- កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាជំរុញឱ្យមានការអប់រំបរិយាបន្នសម្រាប់ពិការភាព តាមរយៈការអនុវត្តគោលនយោបាយផ្សេងៗ គឺបង្ហាញពីការផ្លាស់ប្តូរវិយាបថទៅកាន់ជនមានពិការភាព។ ទោះជាយ៉ាងណាក៏ដោយ តម្រូវឱ្យការបន្សុីគ្នារវាងអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងគំរូសង្គមនៃពិការភាព
- គោលនយោបាយដែលមានស្រាប់ក្នុងប្រទេសកម្ពុជា បង្ហាញពីការផ្តល់នូវការអប់រំផ្សេងៗសម្រាប់កុមារមានពិការភាព ប៉ុន្តែមិនមានន័យថា ទាំងអស់នោះត្រូវតែស្របជាមួយគោលការណ៍សមាហរណកម្មទេ ដោយមានមតិខ្លះលើកឡើងថាកុមារមួយចំនួនត្រូវតែដាក់ឱ្យរៀនដាច់ដោយឡែក
- សិទ្ធិទទួលបាន ការមិនរើសអើង គឺពុំសូវបានបង្ហាញនៅក្នុងគោលនយោបាយទេ ដោយឡែកក្រុមជនងាយរងគ្រោះអាចប្រឈមនឹងការរឹតបន្តឹងបន្ថែម ក៏មិនទាន់បញ្ជាក់ឱ្យច្បាស់ផងដែរ

---

[4] *United Nations Educational, Scientific and Cultural Organization: International Institute for Educational Planning, United Nations Children's Fund, Global Partnership for Education and the United Kingdom Foreign, Commonwealth and Development Office, Education Sector Analysis Methodological Guidelines Volume 3, IIEP-UNESCO and UNICEF, 2021.*

- ទិន្នន័យដែលប្រមូលបានពីមន្ត្រីអប់រំក្រុង ស្រុក ខណ្ឌមួយចំនួន បានស្នើឡើងនូវយន្តការពង្រឹងបន្ថែមទៀត និងទាមទារឱ្យមានគណនេយ្យភាព និងការពង្រឹងគោលនយោបាយឱ្យខ្លាំងឡើង
- គោលនយោបាយបានបង្ហាញពីភាពសំខាន់នៃកិច្ចសហការគ្នាជាមួយស្ថាប័ន និងអ្នកពាក់ព័ន្ធផ្សេងៗ គឺដើម្បីពង្រឹងការគាំទ្រគ្រប់ជ្រុងជ្រោយ ដល់កុមារមានពិការភាព ជាមួយគ្នានេះដែរមន្ត្រីអប់រំក្រុង ស្រុក ខណ្ឌមួយចំនួនស្នើឱ្យមានកិច្ចសហការគ្នាជាវិជ្ជមានកើតមានឡើង។

*ផ្នែកទីពីរនៃការស្រាវជ្រាវផ្តោតលើរបៀបអនុវត្តការអប់រំបរិយាបន្ននៅកម្រិតសាលារៀន។ ការវិភាគលើទិន្នន័យមានស្រាប់ ផ្នែកផ្តត់ផ្គង់រកឃើញថា៖*

- កុមារមានពិការភាពក្នុងប្រទេសកម្ពុជា តិចជាង៣ដងបានចូលរៀនប្រសិនបើប្រៀបធៀបនឹងកុមារមិនមានពិការភាព។ ស្ថានភាពពិការភាពមានផលប៉ះពាល់ខ្លាំងលើការចូលរៀន កត្តាចម្បងៗពាក់ព័ន្ធ គឺទ្រព្យសម្បត្តិ យេនឌ័រ និងទីកន្លែង
- ករណីខ្លះ ទោះបីជាកុមារមានពិការភាពបានចុះឈ្មោះចូលរៀន ក៏ពួកគាត់មិនចូលរៀនពេញម៉ោងដែរ ព្រោះមានកុមារច្រើនលើសចំនួននៅក្នុងថ្នាក់រៀន បញ្ហាក្នុងការដឹកជញ្ជូនទៅសាលារៀនឆ្ងាយៗ និងឧបសគ្គដទៃទៀត
- មិនមានយន្តការកំណត់អត្តសញ្ញាណស្តង់ដា ដោយការទទួលខុសត្រូវនៃការកំណត់អត្តសញ្ញាណផ្អែកលើគ្រូបង្រៀន និងសាលារៀន។ បញ្ហានេះអាចបង្កើតជាកំហុសឆ្គងក្នុងរបាយការណ៍ និងនាំទៅរកកង្វះខាតការជឿទុកចិត្តពីឪពុកម្តាយ អ្នកអាណាព្យាបាល
- មានតែគ្រូបង្រៀនម្នាក់ក្នុងចំណោម១០នាក់បានទទួលការបំប៉នសមត្ថភាព ស្តីពីការអប់រំបរិយាបន្ន។ មានគ្រូបង្រៀនជាច្រើនមានអារម្មណ៍ថាមិនបានត្រៀម លក្ខណៈទុកមុនក្នុងការដោះស្រាយពីតម្រូវការនានាសម្រាប់កុមារមានពិការភាព
- គ្រូបង្រៀន និងនាយកសាលារៀនមួយចំនួនបានរៀបរាប់ថា មានការពេញចិត្តនឹងការអប់រំបរិយាបន្ន ទន្ទឹមនឹងនោះក៏មានគ្រូបង្រៀនខ្លះបានលើកឡើងថា កុមារមានពិការភាពគួរតែរៀនក្នុងថ្នាក់រៀនដាច់ដោយឡែកពីគេ ដែលកត្តានេះអាចឆ្លុះបញ្ចាំងពីកង្វះខាតនៃការយល់ដឹងអំពីនិយមន័យបរិយាបន្ន
- ទោះបីជាមានប្រកាសអន្តរក្រសួង ស្តីពីការដាក់ឱ្យអនុវត្តនូវបទដ្ឋានបច្ចេកទេស ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពក៏ដោយ ក៏ការអនុវត្តនៅតែមានកម្រិតនៅឡើយ ក្នុងការសម្រេចបាននូវសាលារៀន និងថ្នាក់រៀនប្រកបដោយផាសុកភាពពេញលេញ។ គ្រូបង្រៀន និងនាយកសាលារៀនមួយចំនួនបញ្ជាក់ថា មានការជួបប្រទះការប្រឈមជាច្រើនក្នុងការអនុវត្តការអប់រំបរិយាបន្នពីព្រោះពិពិធភាពសម្ភារបង្រៀននៅមានកម្រិត។

***ទោះបីជាកុមារមានពិការភាពអាចទទួលបានការអប់រំក្តី ក៏គុណភាពនៃការអប់រំដែលពួកគេទទួលបានគួរកែលម្អពិសេសគឺ៖***

- លទ្ធផលស្រាវជ្រាវបែបគុណវិស័យបានបង្ហាញឱ្យឃើញថា ភាពខុសគ្នាក្នុងការវាយតម្លៃចំពោះកុមារមានពិការភាព និងកុមារមិនមានពិការភាពយកមកប្រើប្រាស់សឹងតែគ្មានការសម្របសម្រួល

- ស្របពេលនឹងទិន្នន័យការសិក្សារបស់សិស្សមានពិការភាពនៅមានកម្រិត។ លទ្ធផលស្រាវជ្រាវបានបង្ហាញថា ការបញ្ចូលទិន្នន័យសិស្សមានពិការភាព ពិបាកជាងការបញ្ចូលលទ្ធផលសិក្សារបស់សិស្សមិនមានពិការភាព
- ពិការភាពមានទំនាក់ទំនងជាមួយអវត្តមានរយៈពេលយូរ ដែលជះឥទ្ធិពលលើការសិក្សារបស់កុមារមានពិការភាព
- ពិការភាពមានទំនាក់ទំនងជាមួយអត្រាអនក្ខរកម្មខ្ពស់នៅកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ការចូលរៀនបានកាត់បន្ថយអត្រាអនក្ខរកម្មក្នុងចំណោមកុមារមានពិការភាព និងបានកាត់បន្ថយគម្លាតអត្រាអក្ខរកម្មរវាងកុមារមានពិការភាព និងកុមារមិនមានពិការភាព
- ទិន្នន័យបង្ហាញថា អត្ថប្រយោជន៍នៃការអប់រំបរិយាបន្ន និងសាលារៀនអប់រំបរិយាបន្ន អាចពង្រីកសម្រាប់កុមារទាំងអស់នៅកម្ពុជា មិនមែនចំពោះតែកុមារមានពិការភាពនោះទេ។

***នៅពេលពិនិត្យមើលផ្នែកតម្រូវការ ផ្តោតជាសំខាន់លើឥរិយាបថចំពោះការអប់រំកុមារមានពិការភាពនៅក្នុងសាលារៀនទូទៅ ការស្រាវជ្រាវបានសន្និដ្ឋានថា៖***

- ការលើកកម្ពស់ការយល់ដឹងអំពីអត្ថប្រយោជន៍នៃការអប់រំបរិយាបន្នក្នុងសហគមន៍ជាចាំបាច់ ពីព្រោះជំនឿអវិជ្ជមានមួយចំនួននៅតែកើតមានឡើងក្នុងចំណោមឪពុកម្តាយដែលមានកុមារមានពិការភាព និងកុមារមិនមានពិការភាព
- កុមារមានពិការភាពបានរៀបរាប់អំពីការរើសអើង និងការផាត់ចេញពីសង្គមមួយចំនួន អាចនាំឱ្យខ្វះឆន្ទៈក្នុងការចូលរៀននៅសាលារៀនទូទៅ
- បន្ទុកចំណាយមិនផ្ទាល់អាចជះឥទ្ធិពលដល់លទ្ធភាពរបស់អ្នកអាណាព្យាបាល ក្នុងការបញ្ជូនកូនទៅសាលារៀន
- ខណៈដែលការអប់រំនៅកម្ពុជាមិនគិតថ្លៃ អ្នកអាណាព្យាបាលរបស់កុមារមានពិការភាពនៅតែលើកឡើងពីតម្រូវការគាំទ្រផ្នែកថវិកា និងសម្ភារៈបន្ថែមសម្រាប់ការសិក្សា និងការដឹកជញ្ជូន។

***របកគំហើញទាំងនេះបានផ្តល់ជាអនុសាសន៍លើគោលនយោបាយ ដូចខាងក្រោម៖***

## ២.៣ អនុសាសន៍លើគោលនយោបាយ

ដើម្បីអនុវត្តការអប់រំបរិយាបន្ន សម្រាប់ពិការភាព ប្រព័ន្ធនឹងផ្តល់អត្ថប្រយោជន៍ដែលនាំឱ្យមានការផ្លាស់ប្តូរដូចខាងក្រោម៖

### ផ្នែកបរិយាកាសអំណោយផល

- ពង្រឹងគុណភាពការប្រមូលទិន្នន័យកុមារមានពិការភាព និងការសិក្សារបស់ពួកគេ
- កសាងបទដ្ឋានគតិយុត្ត ដើម្បីពិនិត្យតាមដានការអនុវត្តគោលនយោបាយ ដោយធានាឱ្យមានសង្គតិភាពរវាងគោលនយោបាយ និងការអនុវត្តជាក់ស្តែងជាពិសេសរកឃើញពីភាពខ្វះចន្លោះក្នុងការអនុវត្តគោលនយោបាយ
- បន្សុីគ្នាបន្ថែមទៀតរវាងគោលនយោបាយ និងបទដ្ឋានគតិយុត្តជាមួយគំរូសង្គម ឬគំរូសិទ្ធិមនុស្សនៃពិការភាព និងគោលការណ៍អប់រំបរិយាបន្ន

- បង្កើតពិធីសារកំណត់ស្តង់ដា និងឧបករណ៍សម្រាប់កំណត់អត្តសញ្ញាណកុមារទៅតាមប្រភេទពិការភាពផ្សេងៗ និងតម្រូវការសិក្សារបស់ពួកគេ

***ដើម្បីគាំទ្រការអនុវត្តក្នុងកម្រិតផ្តល់សេវា អនុសាសន៍ផ្នែកផ្គត់ផ្គង់នឹងបង្ហាញដូចតទៅ៖***

- កែប្រែសាលារៀនទូទៅឱ្យក្លាយជាសាលារៀនអប់រំបរិយាបន្នឱ្យបានច្រើនដើម្បីសម្របសម្រួលសិស្សមានពិការភាពផ្សេងៗអាចរៀនសូត្របាន
- ពង្រឹងការគាំទ្រផ្នែកហិរញ្ញវត្ថុ និងសម្ភារៈសម្រាប់គ្រួសារ ដែលមានកុមារមានពិការភាព
- ផ្តល់ឱកាសកសាងសមត្ថភាពលើជំនាញវិជ្ជាជីវៈច្បាស់លាស់សម្រាប់គ្រូបង្រៀនដោយផ្តោតលើយុទ្ធសាស្ត្របង្រៀនសិស្សមានពិការភាពឱ្យស្របទៅនឹងតម្រូវការរៀនសូត្រផ្សេងៗប្រកបដោយប្រសិទ្ធភាពនិងធ្វើឱ្យមានការប្រែក្លាយជាថ្នាក់រៀនអប់រំបរិយាបន្ន។

***ផ្នែកគុណភាព ដោយផ្អែកលើលទ្ធផលនៃការស្រាវជ្រាវមានដូចខាងក្រោម៖***

- កសាងកម្មវិធីសិក្សាសមស្រប និងវាយតម្លៃការសិក្សា ដើម្បីតាមដានការរៀនសូត្ររបស់កុមារមានពិការភាព
- បន្តគាំទ្រការរៀនសូត្ររបស់កុមារមានពិការភាពព្រមទាំងតាមដានលើអវត្តមានរយៈពេលវែង និងកាត់បន្ថយការបោះបង់ការសិក្សា។

***ជាទីបញ្ចប់ ដើម្បីធានាការអនុវត្តប្រកបដោយជោគជ័យពីផ្នែកតម្រូវការ មានជាអនុសាសន៍ដូចខាងក្រោម៖***

- លើកកម្ពស់ការអប់រំផ្សព្វផ្សាយអំពីការអប់រំបរិយាបន្នដល់សាធារណជនឱ្យយល់ពីអត្ថប្រយោជន៍របស់កុមារគ្រប់រូប រួមទាំងកុមារមានពិការភាព។ កិច្ចអន្តរាគមន៍សមស្របទៅនឹងបរិបទសង្គម និងវប្បធម៌ បុគ្គលភាព គ្រួសារ សហគមន៍ និងគ្រឹះស្ថានអប់រំគ្រប់កម្រិតនៃសង្គមកម្ពុជា និងផ្តោតលើអាកប្បកិរិយា និងជំនឿអវិជ្ជមានឆ្ពោះទៅរកការលើកកម្ពស់ការអប់រំបរិយាបន្ន
- ជំរុញការចូលរួមរបស់ឪពុកម្តាយក្នុងការចិញ្ចឹមបីបាច់ ថែទាំ និងគាំទ្រកុមារមានពិការភាពឱ្យទទួលបានសេវាផ្សេងៗរួមទាំងការអប់រំបរិយាបន្ន និងសេវាសុខភាព។

## ៣. ចក្ខុវិស័យ

ផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន២០២៤-២០២៨ បង្កើតឡើងដោយផ្អែកលើសមិទ្ធផលនានាដែលមាននៅក្នុងផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន២០១៩-២០២៣ និងមានចក្ខុវិស័យគឺ ផ្តល់ការអប់រំប្រកបដោយគុណភាពដល់ជនមានពិការភាព និងជនមានតម្រូវការពិសេសឱ្យទទួលបានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាដែលជួយអភិវឌ្ឍសក្តានុពលពេញលេញ នឹងចូលរួមអភិវឌ្ឍសង្គមជាតិ។

## ៤. គោលបំណង

ប្រទេសកម្ពុជាទទួលស្គាល់ ការអប់រំបរិយាបន្នមានន័យថា ជាការរាប់បញ្ចូលទាំងសិស្សមានពិការភាពនៅក្នុងសាលារៀនចំណោះទូទៅ។ សព្វថ្ងៃនេះនៅប្រទេសជាច្រើន កុមារមានពិការភាពចូលរៀននៅសាលារៀនចំណោះទូទៅក៏ប៉ុន្តែកម្មវិធីសិក្សាមានភាពបត់បែន។ ដើម្បីឆ្លើយតបទៅនឹងគំរូបរិយាបន្ន (សិស្សមានពិការភាព និងមិនមានពិការភាពរៀនសូត្រតាមកម្មវិធីសិក្សាអប់រំបរិយាបន្នដូចគ្នា)គឺជាដំណើរការរយៈពេលវែង។ វាជាវិធីសាស្ត្រមួយឱ្យប្រព័ន្ធអប់រំមានការផ្លាស់ប្តូររាប់ទាំង រចនាសម្ព័ន្ធ គោលនយោបាយ ការអនុវត្ត និងធនធានមនុស្ស ដើម្បីឱ្យសិស្សទាំងអស់រៀននៅសាលារៀនចំណោះទូទៅមានផាសុកវត្ថុឆ្លើយតបនឹងតម្រូវការរៀនសូត្រផ្សេងៗគ្នា។

ផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន២០២៤-២០២៨ ផ្តល់នូវផែនទីបង្ហាញផ្លូវ យុទ្ធសាស្ត្រ និងសកម្មភាពអាទិភាពសំខាន់ៗ ដើម្បីបង្កើនការចុះឈ្មោះចូលរៀន និងលើកកម្ពស់ការចូលរៀនសមស្របសម្រាប់

សិស្សមានពិការភាពប្រកបដោយ គុណភាព និងបរិយាបន្នរួមទាំងកុមារ វ័យជំទង់ និងយុវជនមានពិការភាព។ ក្នុងន័យនេះរាប់បញ្ចូលទាំងការកំណត់ និងការថែរក្សាឱ្យមានស្តង់ដាការអប់រំបរិយាបន្ន ខ្លឹមសារកម្មវិធីសិក្សាត្រូវសម្របសម្រួលសមស្រប សម្ភារបង្រៀន និងរៀន វិធីសាស្ត្រ និងបរិស្ថានសិក្សាដោយធានាឱ្យបាននូវការចូលរួមការអប់រំបរិយាបន្នប្រកបដោយគុណភាព។

## ៥. វិសាលភាព

ផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន ឆ្នាំ២០២៤-២០២៨ មានគោលបំណងផ្តល់សេវាអប់រំដល់បុគ្គលមានពិការភាព រួមទាំងកុមារ ជនវ័យជំទង់ និងយុវជនមានពិការភាព។ ផែនការសកម្មភាពនេះបង្ហាញថាដើម្បីធានាកុមារទាំងអស់ទទួលបានសេវាអប់រំប្រកបដោយគុណភាព និងបរិយាបន្ន ចាប់ពីមត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សា និងការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ទាំងការអប់រំ ក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ។

## ៦. យុទ្ធសាស្ត្រ

ផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន២០២៤-២០២៨ត្រូវបានបង្កើតឡើងផ្អែកលើអនុសាសន៍ គោលនយោបាយ និងការស្រាវជ្រាវស្តីពីការអប់រំបរិយាបន្ននៅកម្ពុជា តាមរយៈការពិគ្រោះយោបល់ជាច្រើនលើកច្រើនសារ ជាមួយអ្នកពាក់ព័ន្ធមកពីស្ថាប័នផ្សេងៗថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ ឪពុកម្តាយមានកូនមានពិការភាព និងកូនមិនមានពិការភាព។ ផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ននេះបានអនុម័តយុទ្ធសាស្ត្រដូចខាងក្រោម៖

- **យុទ្ធសាស្ត្រ ១ ៖** កសាងក្របខណ្ឌគតិយុត្ត និងបរិយាកាសអំណោយផលដើម្បីលើកកម្ពស់ការអប់រំបរិយាបន្ន
- **យុទ្ធសាស្ត្រ ២ ៖** អភិវឌ្ឍប្រព័ន្ធប្រមូលទិន្នន័យ និងព័ត៌មានដើម្បីកំណត់អត្តសញ្ញាណកុមារមានពិការភាពតាមរយៈកិច្ចសហការជាមួយស្ថាប័នជាតិ និងភាគីពាក់ព័ន្ធ
- **យុទ្ធសាស្ត្រ ៣ ៖** ធានាឱ្យមានការទទួលបានការអប់រំប្រកបដោយគុណភាព និងបរិយាបន្នដល់ជនមានពិការភាព រួមទាំងកុមារនិងជនវ័យជំទង់មានពិការភាព
- **យុទ្ធសាស្ត្រ ៤ ៖** ធានាគុណភាពការអប់រំបរិយាបន្ន ដល់កុមារមានពិការភាព និងកុមារមានតម្រូវការពិសេស
- **យុទ្ធសាស្ត្រ ៥ ៖** អភិវឌ្ឍគំនូសប្លង់ស្តង់ដាសកល សម្រាប់ការសាងសង់អគារសិក្សា សំណង់រូបវន្ត និងការសម្របសម្រួលអនាម័យ
- **យុទ្ធសាស្ត្រ ៦ ៖** ជំរុញឱ្យមានធនធានហិរញ្ញវត្ថុ និងពិពិធភាពសម្រាប់គាំទ្រគ្រួសារងាយរងគ្រោះដែលមានកូនមានពិការភាព និងកុមារមានតម្រូវកាអប់រំពិសេស
- **យុទ្ធសាស្ត្រ ៧ ៖** អភិវឌ្ឍសមត្ថភាពគ្រូ និងគណៈគ្រប់គ្រងសាលារៀន
- **យុទ្ធសាស្ត្រ ៨ ៖** លើកកម្ពស់ការយល់ដឹងពីគោលនយោបាយស្តីពីការអប់រំបរិយាបន្ន
- **យុទ្ធសាស្ត្រ ៩ ៖** ពង្រឹងចំណេះដឹង តួនាទី ការទទួលខុសត្រូវ និងការចូលរួមគ្រប់អ្នកពាក់ព័ន្ធទាំងអស់។

តារាងសង្ខេបអាទិភាពយុទ្ធសាស្ត្រសំខាន់ៗខាងក្រោមនេះ មានបំណងផ្តោតការយកចិត្តទុកដាក់លើអ្នកធ្វើការសម្រេចចិត្តនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងអ្នកផ្តល់សេវា ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ឪពុកម្តាយដែលមានកូនមានពិការភាព ចូលរួមអនុវត្តពេញលេញពិនិត្យតាមដានលើវឌ្ឍនភាព និងវាយតម្លៃផលប៉ះពាល់ពីការអនុវត្តផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន។

| សកម្មភាពចម្បង | សកម្មភាពរយៈពេលមធ្យម (២០២៤-២០២៦) | សកម្មភាពរយៈពេលវែង (២០២៤-២០២៨) |
|---|---|---|
| **យុទ្ធសាស្ត្រ១៖** ការអភិវឌ្ឍក្របខណ្ឌគតិយុត្ត និងបរិយាកាសអំណោយផលដើម្បីលើកកម្ពស់ការអប់រំបរិយាបន្ន។ | ពិនិត្យ និងកែសម្រួលក្របខណ្ឌគតិយុត្តដែលមានស្រាប់អំពីការអប់រំបរិយាបន្ន ដើម្បីជានាសង្គតិភាពជាមួយគោលការណ៍ណែនាំ និងឧបករណ៍ដទៃទៀត។ | ពិនិត្យ និងអភិវឌ្ឍគោលនយោបាយស្តីពីការអប់រំបរិយាបន្ន។ |
| **យុទ្ធសាស្ត្រ២៖** អភិវឌ្ឍប្រព័ន្ធប្រមូលទិន្នន័យ និងព័ត៌មានដើម្បីកំណត់អត្តសញ្ញាណកុមារមានពិការភាពតាមរយៈកិច្ចសហការជាមួយស្ថាប័នជាតិ និងភាគីពាក់ព័ន្ធ។ | ពិនិត្យតាមដាន និងទាញយកវឌ្ឍនភាពអំពីការចុះឈ្មោះចូលរៀន របស់កុមារមានពិការភាព តាមរយៈការវិភាគទិន្នន័យ រួមទាំង ទិន្នន័យរដ្ឋបាលរបស់ ក្រសួងអយក ការស្ទង់មតិ/ការស្រាវជ្រាវ និងការធ្វើប្រជាសាស្ត្រជាតិដទៃទៀត។ | កសាង ផ្អែកលើការអភិវឌ្ឍគោលនយោបាយ (គោលនយោបាយស្តីពីការអប់រំបរិយាបន្ន)។ |
| **យុទ្ធសាស្ត្រ៣៖** ធានាឱ្យមានការទទួលបានការអប់រំប្រកបដោយគុណភាព និងបរិយាបន្នដល់ជនមានពិការភាព រួមទាំងកុមារនិងជនវ័យជំទង់មានពិការភាព។ | គោលការណ៍ណែនាំ អំពីសាលារៀនអប់រំបរិយាបន្ន ត្រូវបានអនុម័ត និងប្រតិបត្តិក្នុងផ្នែកដែលបានជ្រើសរើស។ ក្រសួងអប់រំបន្តផ្តល់ថ្នាក់សមាហរណកម្ម សាលារៀនអប់រំពិសេស ជាទម្រង់ស្ពានចម្លងឆ្ពោះទៅការអប់រំបរិយាបន្ន។ | គោលការណ៍ណែនាំសាលារៀនអប់រំបរិយាបន្ន និងសាលារៀនធនធានត្រូវបានប្រតិបត្តិយ៉ាងទូលំទូលាយ។ |
| **យុទ្ធសាស្ត្រ៤៖** ធានាគុណភាពការអប់រំបរិយាបន្ន ដល់កុមារមានពិការភាព និងកុមារមានតម្រូវការពិសេស។ | អភិវឌ្ឍ និងអនុវត្តកម្មវិធីសិក្សាលម្អិតមានលក្ខណៈបត់បែនដោយយកគំរូ ប្លង់សកលមកប្រើប្រាស់សម្រាប់គោលការណ៍សិក្សា ឧបករណ៍វាយតម្លៃដែលបានអនុម័ត និងផ្តល់សម្ភារសិក្សាបរិយាបន្ន ព្រមទាំងបច្ចេកវិទ្យាជំនួយដែលគាំទ្រដល់តម្រូវការផ្សេងៗនៃកុមារមានពិការភាព។ | ធ្វើការវាយតម្លៃលើការសិក្សានៃកុមារមានពិការភាពជាកាលវិភាគ និងស្ទង់ជាវាយតម្លៃលើការសិក្សាកម្រិតជាតិ។ |
| **យុទ្ធសាស្ត្រ៥៖** អភិវឌ្ឍគំនូសប្លង់ស្តង់ដាសកល សម្រាប់ការសាងសង់អគារសិក្សា សំណង់រូបវន្ត និងការសម្របសម្រួលអនាម័យ។ | - អភិវឌ្ឍ និងធ្វើជាស្តង់ដាគោលការណ៍ណែនាំ ស្តីពីហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងកន្លែងលេងប្រកបដោយផាសុកវត្ត<br>- បញ្ចូលគោលការណ៍សិក្សាតាមគំនូសប្លង់សកលក្នុងសកម្មភាពការបង្រៀន និងការសិក្សា។ | អគារសាលារៀន ហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងៗ(ថ្មី និងត្រូវបានកែលម្អ)អនុលោមតាមស្តង់ដាផាសុកវត្ថុ។ |
| **យុទ្ធសាស្ត្រ៦៖** ជំរុញឱ្យមានធនធានហិរញ្ញវត្ថុ និងពិពិធភាពសម្រាប់គាំទ្រគ្រួសារងាយរងគ្រោះដែលមានកូនមានពិការភាព និងកុមារមានតម្រូវការអប់រំពិសេស។ | - បង្កើតផែនការប្រតិបត្តិប្រចាំឆ្នាំដែលមានការចំណាយថវិកាសមស្រប<br>- វិភាជន៍ថវិការដ្ឋគាំទ្រដល់ការសិក្សារបស់កុមារមានតម្រូវការពិសេស | - ក្រសួងអយក. ផ្តល់សមត្ថភាពសាលារៀនក្នុងការកៀគរកថវិកាគាំទ្រកុមារមានពិការភាពឱ្យទទួលបានសេវាអប់រំ និងសុខភាព |

| សកម្មភាពចម្បង | សកម្មភាពរយៈពេលមធ្យម (២០២៤-២០២៦) | សកម្មភាពរយៈពេលវែង (២០២៤-២០២៨) |
|---|---|---|
| | ធ្វើគម្រោងចំណាយអំពីការអប់រំបរិយាបន្ន សម្រាប់កុមារមានពិការភាព។ | - ធានាការវិភាជន៍ថវិកាគាំទ្រការសិក្សារបស់កុមារមានតម្រូវការពិសេស<br>- ធ្វើខ្ទង់ចំណាយអំពីការអនុវត្តផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្នរយៈពេល៥ឆ្នាំ។ |
| **យុទ្ធសាស្ត្រ៧៖** អភិវឌ្ឍសមត្ថភាពគ្រូ និងគណៈគ្រប់គ្រងសាលារៀន។ | ពិនិត្យ កែសម្រួលកម្មវិធីសិក្សាលម្អិតដែលមានស្រាប់ នឹងត្រូវបានអនុវត្តដោយកម្មវិធីបណ្តុះបណ្តាលដំបូង និងរៀបចំការផ្តល់កម្មវិធីសិក្សាជំនាញលម្អិត និងធ្វើបច្ចុប្បន្នភាពបន្តិចម្តងៗឈានទៅដល់កម្រិតឧត្តមសិក្សា (គឺថាពីសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ទៅបរិញ្ញាបត្ររង និងបរិញ្ញាបត្រ) | - អនុវត្តកម្មវិធីអភិវឌ្ឍន៍អាជីពជាប្រចាំដល់បុគ្គលិកអប់រំ និងគ្រូបង្រៀន<br>- ផ្តល់កម្មវិធីសិក្សាជំនាញលម្អិត និងធ្វើបច្ចុប្បន្នភាពបន្តិចម្តងៗឈានទៅដល់កម្រិត ឧត្តមសិក្សា (គឺថាពីសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ទៅបរិញ្ញាបត្ររង និងបរិញ្ញាបត្រ) ។ |
| **យុទ្ធសាស្ត្រ៨៖** លើកកម្ពស់ការយល់ដឹងពីគោលនយោបាយ ស្តីពីការអប់រំបរិយាបន្ន។ | ពិនិត្យពាក់កណ្តាលអាណត្តិនៃផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន។ | ការវាយតម្លៃចុងក្រោយនៃផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន ការពិនិត្យ និងការអភិវឌ្ឍគោលនយោបាយស្តីពីការអប់រំបរិយាបន្ន។ |
| **យុទ្ធសាស្ត្រ៩៖** ពង្រឹងចំណេះដឹង តួនាទី ការទទួលខុសត្រូវ និងការចូលរួមគ្រប់អ្នកពាក់ព័ន្ធទាំងអស់។ | បញ្ចូលឪពុកម្តាយកុមារមានពិការភាព កុមារមានពិការភាព និងអង្គការជនពិការក្នុងព្រឹត្តិការណ៍សំខាន់ៗនានា រួមទាំងការពិភាក្សាពីគោលនយោបាយ ទិវាជនពិការពិភពលោកប្រារព្ធវេទិកាថ្នាក់ជាតិផ្សេងៗអំពីការអប់រំបរិយាបន្នដើម្បីឆ្លុះបញ្ចាំងពីវឌ្ឍនភាព ស្វែងរកដំណោះស្រាយដែលគាំទ្រដល់សេវាអប់រំសម្រាប់កុមារមានពិការភាព។ | តាមដានវឌ្ឍនភាព និងឥរិយាបថសង្គមផ្លាស់ប្តូរទៅរកការអប់រំបរិយាបន្នសម្រាប់កុមារមានពិការភាព។ |

## ៧. ផែនការសកម្មភាព

ផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្ន ២០២៤-២០២៨ រួមមានយុទ្ធសាស្ត្រចម្បងចំនួន៩ មានគោលបំណង និងលទ្ធផលរំពឹងទុកជាក់លាក់ យុទ្ធសាស្ត្ររង និងសកម្មភាពអាទិភាពសំខាន់ៗដូចបានបង្ហាញនៅក្នុងតារាងលទ្ធផលម៉ាទ្រិច(ភ្ជាប់ក្នុងឧបសម្ព័ន្ធ១)។ ផែនការសមកម្មភាពនេះរួមមានសូចនាករស្នូលសម្រាប់ការពិនិត្យតាមដានវឌ្ឍនភាព និងការវាស់វែងលទ្ធផលដែលបានរៀបចំឡើងសម្រាប់សកម្មភាពអាទិភាពសំខាន់ៗទាំងឡាយដែលបង្ហាញក្នុងយុទ្ធសាស្ត្រទាំង៩ រួមមានចំណុចដៅដែលត្រូវអនុវត្តតាមឆ្នាំនីមួយៗ។

